ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ១៧២៨ សជណ.ណប.ស្ល

រាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# តំបន់ស្នូលព្រែកទាល់ត្រូវបានទទួលស្គាល់ជាតំបន់រ៉ាមសារ

គ្របដណ្តប់លើផ្ទៃដី ២១៣៤២ ហិកតា តំបន់ស្នូលព្រែកទាល់ (បេះដូងនៃបឹងទន្លេសាប) ដែលជាជម្រកពងកូនសត្វស្លាបទឹកធំជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ ត្រូវបានដាក់បញ្ចូលជាតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ (ដែលគេឱ្យឈ្មោះថាជាតំបន់រ៉ាមសារ) ដោយរាជរដ្ឋាភិបាលកម្ពុជា និងត្រូវបានទទួលស្គាល់ដោយលេខាធិការដ្ឋាន រ៉ាមសារស្តីពីតំបន់ដីសើមនាពេលថ្មីៗនេះ។ ការប្រកាសដាក់តំបន់ស្នូលព្រែកទាល់ជាតំបន់រ៉ាមសារទី៤(តំបន់រ៉ាមសារលេខ២២៤៥ https://rsis.ramsar.org/ris/2245) របស់ព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើឡើងនាថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៥ កន្លងទៅ ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា។

តំបន់ស្នូលព្រែកទាល់ ដែលជាជម្រកពងកូនសត្វស្លាបទឹកដ៏ធំជាងគេបំផុត នៅអាស៊ីអាគ្នេយ៍ធ្លាប់ទទួលរងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដោយសារការបរបាញ់ និងការប្រមូលពងកូនសត្វស្លាបហួសកម្រិត ហើយនៅឆ្នាំ១៩៩៩ក្រសួងបរិស្ថានបានសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) ដើម្បីធ្វើការការពារបន្ទាយពងកូនសត្វស្លាបទាំងនោះ។ ជម្រកពងកូនត្រូវបានរួមតូច រហូតដល់ទំហំដែលមាននាពេលបច្ចុប្បន្ននេះ ដោយសារការប្រមូលពងកូនសត្វស្លាបទាំងនោះអស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមក។ អតីតអ្នកប្រមូលពងសត្វជាច្រើនត្រូវបានផ្តល់ការងារជាអ្នកការពារបន្ទាយពងកូនសត្វ និងស្នាក់នៅលើរានដែលសង់នៅលើចុងឈើ ដើម្បីការពារអង្កេត និងតាមដានការពងកូនរបស់សត្វស្លាបទាំងនោះ។ ការការពារនេះត្រូវបានបន្តធ្វើរហូតមកដល់ពេលបច្ចុប្បន្ន ហើយតំបន់ស្នូលព្រែកទាល់នាពេលថ្មីៗនេះ មានសត្វស្លាបទឹករហូតដល់ទៅជាង ៥០០០០ក្បាល កំពុងបន្តពូជ ដែលយ៉ាងហោចណាស់មានសត្វស្លាប ១០ប្រភេទ ដែលជាប្រភេទកំពុងទទួលការគំរាមកំហែងលើពិភពលោក។ តំបន់នេះក៏ជាតំបន់តែមួយគត់ផងដែរនៅអាស៊ីអាគ្នេយ៍ ដែលមានសត្វប្រភេទទុងប្រផេះបន្តពូជ និងមានចំនួនសត្វប្រភេទត្រដក់ធំជិតពាក់កណ្តាលនៃចំនួនសត្វលើពិភពលោក ហើយក៏មានវត្តមានអំបូរនាល និងស្មោញរាប់ពាន់ក្បាលនៅទីនោះ។ ទាំងនេះហើយជាមូលហេតុដែលធ្វើឱ្យតំបន់ស្នូលព្រែកទាល់ ត្រូវបានទទួលស្គាល់ថាជា «**តំបន់រ៉ាមសារ**»។ តំបន់រ៉ាមសារ ព្រែកទាល់បានទាក់ទាញភ្ញៀវទេសចររាប់ពាន់នាក់ក្នុងមួយឆ្នាំៗ ហើយក៏ជាតំបន់ដែលទ្រទ្រង់ដល់ការរស់នៅរបស់ត្រីនៅបឹងទន្លេសាបដែលផ្តល់ផលយ៉ាងសម្បើមផងដែរ។

លោកបណ្ឌិត **Ross Sinclair** ប្រធានអង្គការ WCS ប្រចាំកម្ពុជា បានមានប្រសាសន៍ថា៖ «ប្រទេសកម្ពុជាគួរមានមោទនភាព ដែលតំបន់ស្នូលព្រែកទាល់ត្រូវបានដាក់បញ្ចូលជាតំបន់ដីសើមដែលមាន

R-KH


អគារលេខ៤៨ មហាវិថីសម្តេចព្រះសីហនុ ទន្លេបាសាក់ ចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

សារៈសំខាន់ជាអន្តរជាតិ។ ការដាក់បញ្ចូលនេះគឺជាការទទួលស្គាល់នូវកិច្ចខិតខំប្រឹងប្រែងអភិរក្ស ដែលបានធ្វើឡើងដោយមានកិច្ចសហការរវាងរាជរដ្ឋាភិបាលកម្ពុជា សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ហើយវាក៏ជាការបើកផ្លូវសម្រាប់កិច្ចសហការរបៀបនេះជាច្រើនឆ្នាំទៅមុខទៀត ដើម្បីស្តារ និងការពារតំបន់ស្តូលព្រែកទាល់ឱ្យក្លាយជាតំបន់អច្ឆរិយធម្មជាតិនៃប្រទេសកម្ពុជា»។

លោកបណ្ឌិត **Lew Young** ទីប្រឹក្សាជាន់ខ្ពស់នៃលេខាធិការដ្ឋានអនុសញ្ញារ៉ាមសារប្រចាំអាស៊ីនិងអូសេអានី បានថ្លែងដឹងថា៖ «យើងសូមចូលរួមអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់បញ្ចូលតំបន់ស្តូលព្រែកទាល់ជាតំបន់រ៉ាមសារថ្មី ហើយយើងនឹងបន្តគាំទ្រដល់រដ្ឋាភិបាលកម្ពុជាក្នុងការដាក់តំបន់ដីសើមសំខាន់ៗផ្សេងទៀតឱ្យទៅជាតំបន់រ៉ាមសារ ដូចជាការចូលរួមជានានូវនិរន្តភាពក្នុងការគ្រប់គ្រប់តំបន់រ៉ាមសារទាំងនេះ សម្រាប់បម្រើផលប្រយោជន៍ប្រជាសហគមន៍ និងបរិស្ថាន»។

គួរបញ្ជាក់ថា ៣០% នៃផ្ទៃដីប្រទេសកម្ពុជា គឺគ្របដណ្តប់ដោយតំបន់ដីសើមហើយភាគច្រើននៃតំបន់ដីសើមទាំងនេះ ត្រូវបានរកឃើញថាមានសារសំខាន់ជាអន្តរជាតិ អាស្រ័យដោយវាបានទ្រទ្រង់ដល់ការរស់នៅរបស់ប្រភេទសត្វ និងរុក្ខជាតិដែលកំពុងទទួលរងការគំរាមកំហែង និងឈានដល់ការផុតពូជ។ ក្នុងឆ្នាំ១៩៩៩ កម្ពុជាបានក្លាយជាភាគី ហត្ថលេខីនៃអនុសញ្ញារ៉ាមសារស្តីពីតំបន់ដីសើម ក៏ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះ មានតំបន់ដីសើមតែ ៣ កន្លែងប៉ុណ្ណោះត្រូវបានចាត់បញ្ចូលជាតំបន់រ៉ាមសារដែលក្នុងនោះមាន៖

- តំបន់រ៉ាមសារបឹងឆ្មានិងប្រព័ន្ធព្រែក ( តំបន់រ៉ាមសារលេខ ៩៩៧, https://rsis.ramsar.org/ris/997)
- តំបន់រ៉ាមសារកោះកាពិ( តំបន់រ៉ាមសារលេខ ៩៩៨, https://rsis.ramsar.org/ris/998)
- តំបន់រ៉ាមសារស្ទឹងត្រែង( តំបន់រ៉ាមសារលេខ ៩៩៩, https://rsis.ramsar.org/ris/999)

**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថានបានមានគូសបញ្ជាក់ថា៖ «ការទទួលស្គាល់តំបន់ស្តូលព្រែកទាល់ជាតំបន់រ៉ាមសារ មិនត្រឹមតែផ្តោតទៅលើភាពសំខាន់ជាអន្តរជាតិ នៃតំបន់ដីសើមនេះប៉ុណ្ណោះទេ ប៉ុន្តែវានឹងជាស្ពានសម្រាប់កម្ពុជាក្នុងដាក់បញ្ចូលតំបន់ដីសើមច្រើនទៀតទៅជាតំបន់រ៉ាមសារនាពេលអនាគត»។

អង្គការជីវិតសត្វស្លាបអន្តរជាតិ និងនាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាបនៃក្រសួងបរិស្ថានបានធ្វើការរួមគ្នា ក្នុងការដាក់បញ្ចូលតំបន់ព្រែកទាល់និងតំបន់ដីសើមផ្សេងទៀតជាតំបន់រ៉ាមសារចាប់តាំងពីឆ្នាំ២០០៨ មកម្ល៉េះ។ តំបន់ស្តូលព្រែកទាល់គឺជាតំបន់រ៉ាមសារទីមួយ ដែលត្រូវបានដាក់បញ្ចូលដោយរាជរដ្ឋាភិបាលកម្ពុជាដែលរហូតមកទល់ពេលនេះមានរយៈពេល ១៦ ឆ្នាំមកហើយ។ លោក **ប៊ូ វិសក្ស** នាយកកម្មវិធីអង្គការជីវិតសត្វស្លាបប្រចាំកម្ពុជាក៏បានឱ្យដឹងដែរថា៖ «បន្ថែមលើតម្លៃផ្នែកជីវចម្រុះតំបន់ស្តូលព្រែកទាល់ក៏ជាតំបន់ដែលមានសារសំខាន់សម្រាប់សត្វស្លាប ដែលផ្តល់នូវសេវាអេកូស៊ីជាច្រើនពិសេសគឺ ទិន្នផលត្រីដែលទ្រទ្រង់ដល់ជីវភាពរស់នៅរបស់សហគមន៍ភូមិបណ្តែតទឹក ហេតុដូច្នេះ យើងមានការរីករាយជាខ្លាំងចំពោះលទ្ធផល ដែលទទួលបានមកពីកិច្ចប្រឹងប្រែងក្នុងការដាក់បញ្ចូលតំបន់ស្តូលព្រែកទាល់នេះជាតំបន់រ៉ាមសារ ដែលនឹងអាចទាក់ទាញសហគមន៍អន្តរជាតិឱ្យចាប់អារម្មណ៍បន្ថែមទៀតដល់តំបន់ដ៏អស្ចារ្យមួយនេះ»។

ក្នុងនាមជាប្រទេសហត្ថលេខីនៃអនុសញ្ញារ៉ាមសា ប្រទេសនីមួយៗ ត្រូវដាក់បញ្ចូលតំបន់ដីសើមយ៉ាងតិចមួយ ទៅក្នុងបញ្ជីនៃតំបន់ដីសើមដែលមានសារសំខាន់ជាអន្តរជាតិ ដែលតំបន់ដីសើមទាំងនោះត្រូវ

R ~~tu~~

បានជ្រើសរើសដោយផ្អែកលើភាពសំខាន់ជាអន្តរជាតិនៃអេកូឡូស៊ី រុក្ខសាស្ត្រ សត្វសាស្ត្រ បឹងសាស្ត្រ ឬ ជលសាស្ត្រ។ នៅក្នុងពិភពលោកនាពេលបច្ចុប្បន្នមានតំបន់រ៉ាមសារជាង២២៤០កន្លែង ដែលនេះគឺជាបណ្ដាញគ្រប់គ្រងតំបន់ដីសើមសម្រាប់ការអភិរក្សដ៏ធំជាងគេបំផុត។

ដំណើរការសិក្សានិងការរៀបចំឯកសារ ដាក់តំបន់រ៉ាមសារព្រែកទាល់បានគាំទ្រថវិការពី Darwin Initiative មូលនិធិខ្នាតតូចរបស់ក្រសួងបរិស្ថានជប៉ុន មូលនិធិអភិរក្សធម្មជាតិខេនិនវិន មូលនិធិខ្នាតតូចរ៉ាមសារ និងអង្គការ សមាគមអភិរក្សសត្វព្រៃ។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

**នាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាបនៃក្រសួងបរិស្ថាន**
**បណ្ឌិត ស្រី ស៊ុនលាង** ( ប្រធាននាយកដ្ឋាន )
ទូរស័ព្ទ៖ +855 (0) 77 333 456
អ៊ីម៉ែល៖ kampongspeu@yahoo.com

**អង្គការជីវិតសត្វស្លាបអន្តរជាតិ**
**លោក ប៊ូ វរសក្ស** ( នាយកកម្មវិធីប្រចាំកម្ពុជា )
ទូរស័ព្ទ៖ +855 (0) 12 222 073
អ៊ីម៉ែល៖ vorsak.bou@birdlife.org

**អង្គការសមាគមន៍អភិរក្សសត្វព្រៃ**
**បណ្ឌិត Ross Sinclair** ប្រធានប្រចាំកម្ពុជា
ទូរស័ព្ទ៖ +855 (0) 12 57 87 42
អ៊ីម៉ែល៖ rsinclair@wcs.org